# មន្ទីរកសិកម្មខេត្តកណ្តាល

## មមាចត្នោត




អាស័យដ្ឋានទំនាក់ទំនង ផ្លូវលេខ ១០៣ (តាខ្មៅ)

ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១

(០១២ ៨២៤ ៤២៥



ឧបត្ថម្ភដោយ អង្គការវីវីអូប៊ី VVOB

ឆ្នាំ ២០១០


# មមាចត្នោត

## ១-លក្ខណៈទូទៅ

មមាចត្នោត កើតមានឡើងនៅលើស្រែដែលប្រើប្រាស់ប្រព័ន្ធស្រោចស្រព និងស្រែដែលទទួលរបបទឹកភ្លៀង។ វាអាចកើតមានច្រើនបំផុត នៅពេលដែលមានការប្រើប្រាស់ថ្នាំពុលកសិកម្មមិនបានសមស្របទៅតាមបច្ចេកទេសណែនាំ។ វាចាក់បញ្ចូលពងជាកញ្ចុំទៅក្នុងជាលិកាស្រទបស្លឹក និង នៅលើទ្រនុងស្លឹក។

## ២-លក្ខណៈរូបសាស្ត្រ

-ពង: ជាចង្កោម (រាងដូចស្និតចេក ៧-៨ពង សំបុកពងមានពណ៌ត្នោតអុចមូល) ស្ថិតនៅក្នុងជាលិកាស្រទបស្លឹក និងនៅលើទ្រនុងស្លឹក ហើយមានពណ៌លឿងព្រលែត។ ពងត្រូវការរយៈពេល ៧-៩ ថ្ងៃ ដើម្បីញាស់។

-កូន: កូនទើបញាស់មានពណ៌ត្នោតខ្ចី ហើយមានការវិវឌ្ឍន៍រូបរាងចំនួន ៥ដង ក្នុងរយៈពេល ១៣-១៥ថ្ងៃ មុនក្លាយជាមេ។

-មេចំណាស់ : មានពណ៌ត្នោតចាស់



វដ្តជីវិតរបស់មមាចត្នោតមានរយៈពេល ៣៥ថ្ងៃ។ ពេលពេញវ័យ មមាចត្នោតញីបង្កាត់ជាមួយមមាចត្នោតឈ្មោល រួចពងរហូតដល់វាងាប់។ មមាចត្នោតញីមួយៗអាចពងបានរហូតដល់ ៥០០ ពង។

- មមាចពេញវ័យ: មានរយៈពេល ១២-១៥ថ្ងៃ
- ពង: មានរយៈពេល ៧-៩ថ្ងៃ ទើបញាស់
- កូន: មានរយៈពេល ១៣-១៥ថ្ងៃ




## ៤-ដំណាក់កាលបំផ្លាញ

-បំផ្លាញតិចតួច: នៅដំណាក់កាលសំណាបរហូតដល់ដំណាក់កាលស្រូវបែកគុម្ព។

-បំផ្លាញខ្លាំង: នៅដំណាក់កាលស្រូវកំណត់កំណើតកួររហូតដល់ដំណាក់កាលស្រូវចេញផ្កា។

**៥-ការបំផ្លាញ** ការបំផ្លាញដំណាំស្រូវរបស់មមាចត្នោតមានពីរបែបគឺទីមួយជញ្ជក់យករុក្ខរសពីដើមស្រូវរហូតដល់ដើមស្រូវខ្សោះខ្សោចងាប់ ***(កសិករនិយមហៅថា ក្រាភ្លើង)*** និងទីពីរគឺជាភ្នាក់ងារចម្លងជម្ងឺវីរុសពីរគឺជម្ងឺតឿស្មៅ និងជម្ងឺតឿរួញស្លឹក។

ជាទូទៅមមាចត្នោតច្រើនតែបំផ្លាញ ដំណាំស្រូវធ្ងន់ធ្ងរ ដោយជញ្ជក់យករុក្ខរសតែប៉ុណ្ណោះ។ ចំពោះជម្ងឺតឿស្មៅ និងតឿរួញស្លឹកភាគច្រើនកើតមានលើគុម្ពមួយចំនួនតូចប៉ុណ្ណោះ។



## ៦-វិធានការការពារ និងកំចាត់

៦.១. វិធានការគ្រប់គ្រង និងការអនុវត្តន៍ការដាំដុះ

* អនុវត្តការដាំដុះឱ្យបានដំណាលគ្នា និងធ្វើស្រែតែ ២ដង ក្នុងឆ្នាំ ដោយទុកពេលឱ្យដីស្រែទំនេរ
* ភ្ជួរកប់គល់ជញ្ជ្រាំង និងកាកសំណល់រុក្ខជាតិទៅក្នុងដី
* ជ្រើសរើសពូជស្រូវដែលធន់នឹងមមាចត្នោត
* ថ្នាលសំណាបត្រូវស្ថិតនៅអោយឆ្ងាយពីពន្លឺភ្លើង ករណីប្រើប្រាស់អន្ទាក់ភ្លើងត្រូវធ្វើអោយស្របពេលគ្នា
* បង្ហូរទឹកចេញ (ឬពន្លិចទឹក) ពីស្រែរយៈពេល ៣-៤ថ្ងៃ ក្នុងអំឡុងពេលមានការ ចាប់ផ្តើមរាតត្បាត ឬ បំផ្លាញលើកដំបូង (ដំណាក់កាលលូតលាស់)
* ប្រើប្រាស់ជីអ៊ុយរ៉េអោយបានសមស្រប
* ចិញ្ចឹមត្រីក្នុងស្រែ ឬលែងទាអោយចូលស៊ីមមាចត្នោត
* ពន្លិចទឹកក្នុងស្រែ រួចប្រើស្បៃមុង អូសប្រមូលមមាចត្នោតយកទៅកំទេចចោល។

៦.២. សត្រូវធម្មជាតិ

មានពពួកប៉ារ៉ាស៊ីត និងសត្វរំពារដូចជា រុយ ស្រមោចកន្ទុំរុយ ស្រឹងទឹក ស្រឹងគោក ខ្មូតដី អណ្តើកមាស មេអំបៅ។




ពីងពាង...។ល។ ពួកសត្វទាំងនេះវាចាប់ស៊ីពង កូន និងធ្វើប៉ារ៉ាស៊ីតទៅលើពពួកមមាចត្នោត ។

៦.៣. ការត្រួតពិនិត្យ

ក. ប្រើកន្ត្រកបក់សត្វល្អិត ដើម្បីមើលវត្តមានសត្វល្អិត

ខ. ពិនិត្យមើលគុម្ពស្រូវ ថាតើមាន:

- វត្តមាននៃមមាចត្នោត ឬទេ?
- ដើមស្រូវផ្នែកគល់មានដុះផ្សិត ឬទេ?
- ស្លាកស្នាមនៃសំណាកមមាចត្នោត ឬទេ?
- ពីងពាងធ្វើសំណាញ់ច្រើន ឬទេ?
- ការលូតលាស់ខ្សោយឬចេញអុតលើស្លឹក ឬទេ?

**ការប្រើប្រាស់ថ្នាំកសិកម្មជាជំរើសចុងក្រោយបង្អស់ក្នុងការកំចាត់មមាចត្នោត:**

- ប៊ុយប្រូហ្វេហ្សីន (Buprofesinឬ Butyl 10WP ឬ Applaud 10WP) ប្រើថ្នាំ ៤០ក្រាម លាយទឹក ១៦លីត្រ សំរាប់បាញ់លើ ផ្ទៃដី ៤០០ម$^{២}$ (ឬ១ គក្រ/ ហិចតា)
- ហ្វេណូប៊ុយកាប (Fevnobuykab ឬ Bacide 50EC ) ប្រើ ៤០-៦០ មីលីលីត្រ លាយទឹក ១៦ លីត្រ បាញ់លើផ្ទៃដី ៤០០ ម$^{២}$
- អូស៊ីន (Osfen 20WP= ឬ dinotefuran) ប្រើ៦,៥ក្រាម លាយទឹក១៦លីត្រ សំរាប់បាញ់លើផ្ទៃដី៥០០ម$^{២}$។
- ត្រៃបុង (Trebon 10 EC) ប្រើ ១,៥០លីត្រ/ ហិចតា

(ដើម្បីសុវត្ថិភាព និងជាប្រយោជន៍របស់លោកអ្នក សូមប្រើប្រាស់តែថ្នាំកសិកម្មដែលបានចុះបញ្ជិកា និងអនុវត្តអោយបានត្រឹមត្រូវតាមការណែនាំក្នុងស្លាកសញ្ញា)